LBUSD STORM SAFETY AND PREPAREDNESS GUIDE

LBUSD SAFETY MEASURES

The Long Beach Unified School District Emergency Preparedness Program has established a comprehensive school safety plan to promote and prepare safe, secure schools. Each year, school safety teams review emergency plans and response activities for earthquakes, fires, floods, power failures, severe weather, threats, and other events. To maintain readiness, students, teachers, principals, and staff participate in emergency drills and exercises throughout the year. Students of all grade levels will practice these steps.

We encourage families to talk to their child about the importance of following the directions of their teachers and principal during an emergency. Family members can learn more about a school's emergency plan by attending site council meetings and by being involved in safety meetings. If you have questions, please contact the school principal. You may also contact the Emergency Preparedness Program Manager for more information at 562-997-8336.

REMINDERS: Please take extra precautions when walking or driving to and from school. Allow extra time for travel, avoid puddled or flooded areas, and use caution near crosswalks. Maintenance crews proactively trim trees, clear gutters and storm drains, and place sandbags in known flooding areas to help keep campuses safe under rainy weather.





CITY OF LONG BEACH EMERGENCY NOTIFICATIONS

Sign up with Alert Long Beach to receive city emergency notifications by text and/or email. In the event of an emergency, severe weather, or any incident that impacts city operations, a text message and/or voice message will be sent to the cell number and/or email address that you specify.


SANDBAG DISTRIBUTION AND FLOOD PREPAREDNESS

City of Long Beach Sandbag Distribution:
Empty sandbags are available at all Long Beach Fire Department neighborhood fire stations. Long Beach residents can obtain these sandbags only by presenting valid identification. Each resident may obtain up to 10 bags. Residents are encouraged to bring their own shovels or other tools to fill the sandbags. Those who fill sandbags now are encouraged to store and reuse them as needed throughout the winter storm season. **Find Long Beach Fire Department stations**.

Municipal Safety Resources:

- City of Long Beach Storm Safety Guide
- City of Lakewood Preparedness Guide
- City of Signal Hill Emergency Guide
- City of Carson Home Safety and Storms Guide
- City of Avalon Storm Information





LONG BEACH CITY EMERGENCY TIPS

- Build an Emergency Kit: Prepare an emergency kit with essential daily items to be self-sustaining for at least five days, including canned and shelf-stable food, water, and medication for each family member, a first aid kit, a flashlight, extra batteries, and comfort items for people and pets. Remember to maintain your kit by replacing expired items and updating it as your family's needs change.
- Identify areas around your home or business that may be vulnerable to flooding and take steps to protect them.
- Secure outdoor furniture and other loose objects before high winds arrive, and keep leaves, trash, and other debris out of storm drains.
- Prepare for possible power outages by charging electronic devices and having emergency lighting available.
- Stay away from downed power lines, fallen trees, and flooded streets.
- Report street flooding or downed trees by calling 562-570-2700.
- Report downed power lines by calling 9-1-1.
- Report a clogged storm catch basin, downed trees, and damaged traffic signals or streetlights on the **Go Long Beach app** or online portal. Emergency crews are on standby for urgent needs.
- To check the status of street sweeping in localized areas, call 562-570-2890.

FLOOD ZONE MAP AND POWER OUTAGES

You can look up your home and neighborhood's flood risk using FEMA's flood map. Areas in designated low-lying zones are particularly susceptible to flooding, and you may want to take extra precautions.

If you lose power, you can check your outage status and restoration times through Southern California Edison (SCE). SCE also provides resources on what to do if you see a downed power line or other electrical safety concern. Long Beach's Public Works Department has plans ready for when a large storm rolls in and does regular maintenance on 5,600 catch basins, which feed storm drains, and it prioritizes street sweeping and cleaning of catch basins and storm drains in flood-prone areas during wet weather. If you see a blocked catch basin or backed-up storm drain, you can report it through the GoLongBeach app or by calling 562-570-2700. Officials advise people not to walk or drive through flooded areas, as the water can be deeper than it appears.



GUÍA DE SEGURIDAD Y PREPARACIÓN DEL LBUSD ANTE TORMENTAS

MEDIDAS DE SEGURIDAD DEL LBUSD

El Programa de Preparación para Emergencias de LBUSD ha establecido un plan integral de seguridad escolar para promover y mantener entornos escolares seguros y protegidos. Cada año, los equipos de seguridad escolar revisan los planes de emergencia y los procedimientos de respuesta ante terremotos, incendios, inundaciones, cortes de energía eléctrica, condiciones meteorológicas extremas, amenazas y otros incidentes. Para mantenerse preparados, los estudiantes, y demás miembros del personal participan en simulacros y ejercicios de emergencia durante todo el año. Los estudiantes de todos los grados practicarán estos procedimientos.



Animamos a las familias a conversar con sus hijos sobre la importancia de seguir las instrucciones de sus maestros y del director durante una emergencia. Las familias pueden obtener más información sobre el plan de emergencia de su escuela al asistir a las reuniones del consejo escolar y participar en las reuniones de seguridad. Si tiene preguntas, comuníquese con el director de la escuela. También puede comunicarse con la persona encargada del Programa de Preparación para Emergencias al 562-997-8336 para obtener más información.

RECORDATORIOS: Tome precauciones al ir y regresar de la escuela. Salga con tiempo, evite zonas inundadas y tenga cuidado en los cruces peatonales. El personal de mantenimiento poda árboles, limpia desagües y coloca sacos de arena para mantener seguros los planteles durante las lluvias.



NOTIFICACIONES DE EMERGENCIA DE LA CIUDAD DE LONG BEACH

Regístrese en Alert Long Beach para recibir notificaciones de emergencia de la ciudad por mensaje de texto y/o correo electrónico. En caso de emergencia, condiciones meteorológicas extremas o incidentes que afecten los servicios de la ciudad, recibirá una alerta por mensaje de texto, mensaje de voz y/o correo electrónico, según los datos de contacto que proporcione.

DISTRIBUCIÓN DE SACOS DE ARENA Y PREPARACIÓN ANTE INUNDACIONES


Distribución de sacos de arena de la Ciudad de Long Beach:
Hay sacos de arena vacíos disponibles en todas las estaciones de bomberos de Long Beach. Para obtenerlos, los residentes de Long Beach deben presentar una identificación válida. Cada residente puede recibir hasta 10 sacos. Se recomienda traer palas u otras herramientas para llenarlos, así como guardarlos y reutilizarlos según sea necesario durante la temporada de tormentas invernales. **Encuentre las estaciones de bomberos de Long Beach.**



Recursos municipales de seguridad:

- Guía de seguridad ante tormentas de la Ciudad de Long Beach
- Guía de preparación de la Ciudad de Lakewood
- Guía de emergencias de la Ciudad de Signal Hill
- Guía de seguridad en el hogar y ante tormentas de la Ciudad de Carson
- Información sobre tormentas de la Ciudad de Avalon

CONSEJOS DE LA CIUDAD DE LONG BEACH PARA EMERGENCIAS



- Prepare un kit de emergencia: Incluya artículos esenciales para cubrir las necesidades de su familia durante al menos cinco días: alimentos enlatados y no perecederos, agua, medicamentos para cada integrante, un botiquín de primeros auxilios, una linterna, pilas adicionales y artículos de confort para personas y mascotas. Reemplace los productos vencidos y actualice el kit según cambien las necesidades de su familia.
- Identifique las zonas de su hogar o negocio propensas a inundaciones y tome medidas para protegerlas.
- Asegure los muebles de exterior y otros objetos sueltos antes de que lleguen vientos fuertes. Mantenga los desagües pluviales libres de hojas, basura y otros residuos.
- Prepárese para posibles cortes de energía eléctrica: cargue sus dispositivos electrónicos y tenga iluminación de emergencia disponible.
- Manténgase alejado de cables eléctricos caídos, árboles derribados y calles inundadas.
- Reporte inundaciones en las calles o árboles caídos llamando al 562-570-2700.
- Reporte cables eléctricos caídos llamando al 9-1-1.
- Reporte sumideros pluviales obstruidos, árboles caídos, semáforos dañados o fallas del alumbrado público mediante la aplicación o el portal en línea de **Go Long Beach**. Los equipos de emergencia están disponibles para atender necesidades urgentes.
- Para consultar el estado del servicio de barrido de calles en su zona, llame al 562-570-2890.

MAPA DE ZONAS INUNDABLES Y CORTES DE ENERGÍA ELÉCTRICA

Puede consultar el riesgo de inundación de su hogar y vecindario en el mapa de inundaciones de FEMA. Las zonas bajas identificadas en el mapa son especialmente propensas a inundaciones, por lo que se recomienda tomar precauciones adicionales.



Si se queda sin electricidad, puede consultar el estado del corte y los tiempos estimados de restablecimiento del servicio en Southern California Edison (SCE). SCE también ofrece recursos sobre qué hacer si ve un cable eléctrico caído o detecta otro riesgo eléctrico. El Departamento de Obras Públicas de Long Beach cuenta con planes para responder a tormentas fuertes y realiza mantenimiento periódico de 5,600 sumideros conectados al sistema de drenaje pluvial. Durante las lluvias, da prioridad al barrido de calles y a la limpieza de sumideros y desagües pluviales en zonas propensas a inundaciones.
Si observa un sumidero obstruido o un desagüe pluvial desbordado, repórtelo mediante la **aplicación GoLongBeach** o llamando al 562-570-2700. Las autoridades recomiendan no caminar ni conducir por zonas inundadas, ya que el agua puede ser más profunda de lo que parece.

មគ្គុទ្ទេសក៍ស្តីពីសុវត្ថិភាព និងការត្រៀមខ្លួនសម្រាប់ព្យុះរបស់មណ្ឌលសិក្សាធិការរួមឡុងបិច

វិធានការសុវត្ថិភាពរបស់មណ្ឌលសិក្សាធិការរួមឡុងបិច



កម្មវិធីត្រៀមបង្ការគ្រោះអាសន្ន របស់មណ្ឌលសិក្សាធិការរួមឡុងបិច បានបង្កើតផែនការសុវត្ថិភាពសាលារៀនដ៏ទូលំទូលាយ ដើម្បីលើកកម្ពស់ និងរៀបចំឱ្យសាលារៀនមានសុវត្ថិភាព និងសន្តិសុខ។ ជារៀងរាល់ឆ្នាំ ក្រុមការងារសុវត្ថិភាពសាលារៀនពិនិត្យឡើងវិញនូវផែនការគ្រោះអាសន្ន និងសកម្មភាពឆ្លើយតបចំពោះការរញ្ជួយដីអគ្គិភ័យ ទឹកជំនន់ ការដាច់ចរន្តអគ្គិសនី អាកាសធាតុធ្ងន់ធ្ងរ ការគំរាមកំហែង និងហេតុការណ៍ផ្សេងៗ។ ដើម្បីរក្សាភាពត្រៀមខ្លួនជានិច្ច សិស្ស គ្រូបង្រៀន នាយកសាលា និងបុគ្គលិកចូលរួមក្នុងការហាត់សម និងលំហាត់អនុវត្តសម្រាប់គ្រោះអាសន្នពេញមួយឆ្នាំ។ សិស្សគ្រប់កម្រិតថ្នាក់នឹងអនុវត្តនីតិវិធីទាំងនេះ។

យើងលើកទឹកចិត្តឱ្យក្រុមគ្រួសារពិភាក្សាជាមួយកូនអំពីសារៈសំខាន់នៃការធ្វើតាមការណែនាំរបស់គ្រូបង្រៀន និងនាយកសាលាក្នុងពេលមានគ្រោះអាសន្ន។ សមាជិកគ្រួសារអាចស្វែងយល់បន្ថែមអំពីផែនការគ្រោះអាសន្នរបស់សាលា តាមរយៈការចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាសាលា និងកិច្ចប្រជុំស្តីពីសុវត្ថិភាព។ ប្រសិនបើលោកអ្នកមានសំណួរ សូមទាក់ទងនាយកសាលា។ លោកអ្នកក៏អាចទាក់ទងអ្នកគ្រប់គ្រងកម្មវិធីត្រៀមបង្ការគ្រោះអាសន្ន តាមលេខ ៥៦២-៩៩៧-៨៣៣៦ ដើម្បីទទួលបានព័ត៌មានបន្ថែម។

សូមរំលឹក៖ សូមបង្កើនការប្រុងប្រយ័ត្នពេលដើរ ឬបើកបរទៅមកសាលារៀន។ ទុកពេលបន្ថែមសម្រាប់ការធ្វើដំណើរ ជៀសវាងកន្លែងមានទឹកដក់ ឬលិចទឹក និងប្រុងប្រយ័ត្ននៅជិតគំនូសផ្លូវសម្រាប់អ្នកថ្មើរជើង។ ក្រុមការងារថែទាំកាត់មែកឈើ សម្អាតចង្ករទឹក និងលូបង្ហូរទឹកភ្លៀង ព្រមទាំងដាក់បាវខ្សាច់នៅតំបន់ដែលងាយលិចទឹកជាមុន ដើម្បីជួយរក្សាសុវត្ថិភាពក្នុងបរិវេណសាលារៀនពេលមានភ្លៀង។



ការជូនដំណឹងអំពីគ្រោះអាសន្នរបស់ទីក្រុងឡុងបិច

ចុះឈ្មោះក្នុងប្រព័ន្ធជូនដំណឹងរបស់ទីក្រុងឡុងបិច ដើម្បីទទួលបានការជូនដំណឹងអំពីគ្រោះអាសន្នរបស់ទីក្រុងតាមសារជាអក្សរ និង/ឬអ៊ីមែល។ ក្នុងករណីមានគ្រោះអាសន្ន អាកាសធាតុធ្ងន់ធ្ងរ ឬហេតុការណ៍ណាមួយដែលប៉ះពាល់ដល់ដំណើរការរបស់ទីក្រុង សារជាអក្សរ និង/ឬសារជាសំឡេងនឹងត្រូវបានផ្ញើទៅលេខទូរសព្ទដៃ និង/ឬអាសយដ្ឋានអ៊ីមែលដែលលោកអ្នកបានផ្តល់។


ការចែកចាយបាវខ្សាច់ និងការត្រៀមបង្ការទឹកជំនន់



ការចែកចាយបាវខ្សាច់របស់ទីក្រុងឡុងបិច៖
បាវខ្សាច់ទទេមាននៅគ្រប់ស្ថានីយពន្លត់អគ្គិភ័យក្នុងសង្កាត់នានារបស់នាយកដ្ឋានពន្លត់អគ្គិភ័យទីក្រុងឡុងបិច។ អ្នករស់នៅទីក្រុងឡុងបិចត្រូវបង្ហាញឯកសារបញ្ជាក់អត្តសញ្ញាណដែលមានសុពលភាព ដើម្បីទទួលបានបាវទាំងនេះ។ អ្នករស់នៅម្នាក់អាចទទួលបានរហូតដល់ ១០ បាវ។ សូមយកប៉ែល ឬឧបករណ៍ផ្សេងទៀតមកដោយខ្លួនឯង ដើម្បីច្រកខ្សាច់ចូលបាវ។ អ្នកដែលច្រកខ្សាច់ទុកឥឡូវនេះ គួររក្សាទុក និងប្រើប្រាស់បាវទាំងនោះឡើងវិញតាមតម្រូវការ ពេញមួយរដូវព្យុះរងា។
ស្វែងរកទីតាំងស្ថានីយពន្លត់អគ្គិភ័យទីក្រុងឡុងបិច។

ធនធានសុវត្ថិភាពរបស់ទីក្រុងនានា៖
- មគ្គុទ្ទេសក៍សុវត្ថិភាពពេលមានព្យុះរបស់ទីក្រុងឡុងបិច
- មគ្គុទ្ទេសក៍ត្រៀមបង្ការរបស់ទីក្រុងឡេកវូដ
- មគ្គុទ្ទេសក៍គ្រោះអាសន្នរបស់ទីក្រុងស៊ីកណលហ៊ីល
- មគ្គុទ្ទេសក៍សុវត្ថិភាពក្នុងផ្ទះ និងពេលមានព្យុះរបស់ទីក្រុងខាសុន
- ព័ត៌មានអំពីព្យុះរបស់ទីក្រុងអាវ៉ាឡុន

គន្លឹះសម្រាប់គ្រោះអាសន្នរបស់ទីក្រុងឡុងបិច



- រៀបចំសម្ភារៈសង្គ្រោះបន្ទាន់៖ ត្រៀមសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃចាំបាច់ ដើម្បីឱ្យគ្រួសាររបស់លោកអ្នកអាចផ្គត់ផ្គង់តម្រូវការដោយខ្លួនឯងបានយ៉ាងហោចណាស់ប្រាំថ្ងៃ។ សម្ភារៈទាំងនេះរួមមាន អាហារកំប៉ុង និងអាហារដែលអាចរក្សាទុកបានយូរដោយមិនចាំបាច់ដាក់ទូទឹកកក ទឹក និងថ្នាំពេទ្យសម្រាប់សមាជិកគ្រួសារម្នាក់ៗ ប្រអប់សង្គ្រោះបឋម ពិល ថ្មបន្ថែម និងរបស់របរដែលជួយឱ្យមនុស្ស និងសត្វចិញ្ចឹមមានអារម្មណ៍កក់ក្តៅ និងស្រួលចិត្ត។ សូមកុំភ្លេចជំនួសរបស់ដែលផុតកំណត់ប្រើប្រាស់ និងកែសម្រួលសម្ភារៈទាំងនេះឱ្យស្របតាមតម្រូវការដែលផ្លាស់ប្តូររបស់គ្រួសារ។
- កំណត់តំបន់ជុំវិញផ្ទះ ឬអាជីវកម្មរបស់លោកអ្នកដែលអាចងាយរងទឹកជំនន់ ហើយចាត់វិធានការការពារតំបន់ទាំងនោះ។
- ចង ឬដាក់គ្រឿងសង្ហារឹមខាងក្រៅ និងវត្ថុរលុងផ្សេងៗឱ្យបានរឹងមាំ មុនពេលមានខ្យល់ខ្លាំង ហើយរក្សាលូបង្ហូរទឹកភ្លៀងឱ្យគ្មានស្លឹកឈើ សំរាម និងកាកសំណល់ផ្សេងៗ។
- ត្រៀមខ្លួនសម្រាប់ការដាច់ចរន្តអគ្គិសនីដែលអាចកើតមាន ដោយសាកថ្មឧបករណ៍អេឡិចត្រូនិក និងត្រៀមភ្លើងបំភ្លឺសម្រាប់គ្រោះអាសន្ន។
- នៅឱ្យឆ្ងាយពីខ្សែភ្លើងធ្លាក់ដី ដើមឈើរលំ និងផ្លូវដែលលិចទឹក។
- រាយការណ៍អំពីផ្លូវលិចទឹក ឬដើមឈើរលំ ដោយទូរសព្ទទៅលេខ ៥៦២-៥៧០-២៧០០។
- រាយការណ៍អំពីខ្សែភ្លើងធ្លាក់ដី ដោយទូរសព្ទទៅលេខ ៩-១-១។
- រាយការណ៍អំពីអណ្តូងប្រមូលទឹកភ្លៀងដែលស្ទះ ដើមឈើរលំ ភ្លើងសញ្ញាចរាចរណ៍ខូច ឬភ្លើងបំភ្លឺផ្លូវខូច តាមកម្មវិធី ឬគេហទំព័រ ហ្គោឡុងបិច។ ក្រុមសង្គ្រោះបន្ទាន់ត្រៀមរួចជាស្រេច ដើម្បីឆ្លើយតបនឹងតម្រូវការបន្ទាន់។
- ដើម្បីពិនិត្យស្ថានភាពសេវាបោសសម្អាតផ្លូវក្នុងតំបន់របស់លោកអ្នក សូមទូរសព្ទទៅលេខ ៥៦២-៥៧០-២៨៩០។

ផែនទីតំបន់ប្រឈមនឹងទឹកជំនន់ និងការដាច់ចរន្តអគ្គិសនី



លោកអ្នកអាចពិនិត្យហានិភ័យទឹកជំនន់នៅផ្ទះ និងក្នុងសង្កាត់របស់លោកអ្នក តាមរយៈផែនទីទឹកជំនន់របស់ទីភ្នាក់ងារគ្រប់គ្រងគ្រោះអាសន្នសហព័ន្ធ។ តំបន់ដីទាបដែលបានកំណត់ក្នុងផែនទីងាយរងទឹកជំនន់ជាពិសេស ដូច្នេះលោកអ្នកគួរបង្កើនការប្រុងប្រយ័ត្ន។

ប្រសិនបើដាច់ចរន្តអគ្គិសនី លោកអ្នកអាចពិនិត្យស្ថានភាពនៃការដាច់ភ្លើង និងពេលវេលាប៉ាន់ស្មាននៃការផ្គត់ផ្គង់ឡើងវិញ តាមរយៈក្រុមហ៊ុនអគ្គិសនី សៅធើន កាលីហ្វ័រញ៉ា អេឌីសុន។ ក្រុមហ៊ុននេះក៏ផ្តល់ព័ត៌មានណែនាំអំពីអ្វីដែលត្រូវធ្វើ ប្រសិនបើលោកអ្នកឃើញខ្សែភ្លើងធ្លាក់ដី ឬបញ្ហាសុវត្ថិភាពអគ្គិសនីផ្សេងទៀត។
នាយកដ្ឋានសាធារណការរបស់ទីក្រុងឡុងបិចមានផែនការត្រៀមរួចជាស្រេចសម្រាប់ព្យុះធំៗ និងថែទាំអណ្តូងប្រមូលទឹកភ្លៀងចំនួន ៥.៦០០ ដែលបង្ហូរទឹកចូលទៅក្នុងប្រព័ន្ធលូជាប្រចាំ។ ក្នុងអំឡុងពេលមានភ្លៀង នាយកដ្ឋានផ្តល់អាទិភាពដល់ការបោសសម្អាតផ្លូវ និងការសំអាតអណ្តូងប្រមូលទឹកភ្លៀង និងលូបង្ហូរទឹកភ្លៀងនៅតំបន់ងាយរងទឹកជំនន់។
ប្រសិនបើលោកអ្នកឃើញអណ្តូងប្រមូលទឹកភ្លៀងដែលស្ទះ ឬលូបង្ហូរទឹកភ្លៀងដែលទឹកហូរមិនទាន់ សូមរាយការណ៍តាមកម្មវិធីហ្គោឡុងបិច ឬទូរសព្ទទៅលេខ ៥៦២-៥៧០-២៧០០។ អាជ្ញាធរណែនាំកុំឱ្យដើរ ឬបើកបរឆ្លងកាត់តំបន់លិចទឹក ព្រោះទឹកអាចជ្រៅជាងអ្វីដែលមើលឃើញ។